**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
ក្រុមការងាររបាយការណ៍ ព័ត៌មានវិទ្យា និងរូបភាព
ក្រុមទី៤ (កិច្ចប្រជុំត្រីភាគី កម្ពុជា វៀតណាម ឡាវ)

# កំណត់ហេតុ

កិច្ចប្រជុំត្រីភាគី កម្ពុជា ឡាវ វៀតណាម ស្តីពី កិច្ចសហការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ ឆ្លងកាត់ព្រំដែន ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

ថ្ងៃចន្ទ-អង្គារ ៨-៩ រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៣-២៤ ខែធ្នូ ឆ្នាំ២០២៤ នៅសណ្ឋាគារ Empress Angkor Resort & Spa ខេត្តសៀមរាប មានរៀបចំកិច្ចប្រជុំត្រីភាគី កម្ពុជា ឡាវ វៀតណាម ស្តីពី កិច្ចសហការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែន ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

## គោលបំណង នៃកិច្ចប្រជុំ ៖

១.ផ្លាស់ប្តូរព័ត៌មាន អំពីនិន្នាការនៃបទល្មើស និន្នាការនៃប្រជាពលរដ្ឋដែលធ្វើចំណាកស្រុក ស្ថានភាពនៃភាពងាយរងគ្រោះរបស់ជនទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែន នៃប្រទេសទាំងបី និងបទពិសោធន៍ក្នុងការដោះស្រាយបញ្ហាប្រឈម

២.សិក្សាអំពីយន្តការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែន របស់រដ្ឋាភិបាលនៃប្រទេសទាំងបី ភាពប្រឈមលើការអនុវត្តយន្តការដែលមានស្រាប់ និងកិច្ចសហការរវាងប្រទេសទាំងបី ក្នុងការទប់ស្កាត់ការកេងប្រវ័ញ្ច និងជួញដូរមនុស្សឆ្លងដែន

៣.ស្វែងរកដំណោះស្រាយរួម ដើម្បីបង្កើនប្រសិទ្ធិភាពក្នុងការគ្រប់គ្រងលំហូរឆ្លងកាត់ព្រំដែន និងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ សំដៅដល់ការធ្វើទេសន្តរប្រវេសន៍ ប្រកបដោយសុវត្ថិភាព រៀបរយនិងស្របច្បាប់

៤.គំនិតផ្តួចផ្តើម លើកទិសដៅក្នុងការបង្កើតយន្តការត្រីភាគី និងនីតិវិធីជាក់លាក់ដែលឯកភាពគ្នាសម្រាប់ការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ រៀបចំកិច្ចប្រជុំទៀងទាត់ ដើម្បីចែករំលែកព័ត៌មាន និងកិច្ចសហការបន្ត ។

## I.សមាសភាពគណៈប្រតិភូទាំង ៣ ប្រទេស

- ភាគីព្រះរាជាណាចក្រកម្ពុជា

1. លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
2. ឯកឧត្តម ហ៊ូ វុឌ្ឍី រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
3. ឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
4. លោកជំទាវ ឡុង សុផល្លី រដ្ឋលេខាធិការក្រសួងកិច្ចការនារី
5. ឯកឧត្តម អ៊ឹង វ៉ាន់ថា តំណាងក្រសួងការបរទេស និងសហប្រតិបត្តការអន្តរជាតិ

6. លោកជំទាវ ឧត្តមសេនីយ៍ឯក ប៊ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ
7. ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី អគ្គស្នងការរងនគរបាលជាតិ
8. ឯកឧត្តម ឧត្តមសេនីយ៍ឯក សុខ សុមនា អគ្គយនាករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍
9. លោក សំកុល សុចិត្រា អភិបាលរងខេត្តសៀមរាប

- ភាគីសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

1. General Khongsavat BOUNLIENG: Deputy Chief of Lao Police, General Department of Police, Party of National Committee on Anti Trafficking in Person.
2. Col. Kikeo CHANTHALANGSY: Director General of Anti-Human Department, General Department of Police.
3. Mr. Phetsamone KEOVONGVICHITH: Deputy Director General of International Organization Department.
4. Pol. Col Kidone KIVONGXAY: Head of Division Immigration Department
5. Po.Major Inpong LOUANGPANYA Head of the Secretariat Division to the NCATIP, Anti-Human Trafficking Department.
6. Ms. Minlavone DALASENE: Head of the Office of the Counseling and Protection Center for Women and Children.
7. Mr. Souksakhone SIHARAJ: Deputy Chief of Oversea Employment Division, Employment Department.
8. Mr. Soudchayxiong: Laos Embassy

- ភាគីសាធារណរដ្ឋសង្គមនិយមវៀតណាម

9. Senior Col. Vu Van Dau: Deputy Director General Criminal Police Department.
10. Senior Col. Pham Long Bien: Head of Division, Counter Narcotics Department.
11. Col. Nguyen Trung Hieu: Head of Division.
12. Col. Ho Thi Hong Anh: Deputy Head of Division.
13. Col. Ngo Xuan Y: Deputy Head of Division.
14. Col. Doan Van Dac: Deputy Head of Division.
15. Lieut. Nguyen Viet Anh: Office of Department of Foreign Relations.

## II.សមាសភាពចូលរួម

1. លោក ង៉ិល សុវណ្ណារិទ្ធ ព្រះរាជអាជ្ញារង នៃសាលាដំបូងខេត្តសៀមរាប
2. លោក ឧត្តមសេនីយ៍ទោ សុខ សំបូរ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
3. លោក យូ សុក័ក្រ ប្រធាននាយកដ្ឋាន ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា
4. លោក ឧត្តមសេនីយ៍ទោ ខេង រ៉ា អនុប្រធាននាយកដ្ឋានកណ្តាលព្រំដែន
5. លោក ឧត្តមសេនីយ៍ទោ រស់ សុខជឿន អនុប្រធាននាយកដ្ឋាននគរបាលការពារព្រំដែនទឹក
6. លោក ឧត្តមសេននីយ៍ត្រី ដួង ស៊ីហៃ អនុប្រធាននាយកដ្ឋាននគរបាលការពារព្រំដែនគោក
7. លោក ស៊ុន សេងហុក ប្រធាននាយកដ្ឋាន ក្រសួងអប់រំ យុវជន និងកីឡា
8. លោក ឧត្តមសេនីយ៍ទោ ភឿន លីវិន្ត ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តរតនគីរី
9. លោកស្រី ឧត្តមសេនីយ៍ត្រី ដួង ថាវរី ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប
10. លោក ឧត្តមសេនីយ៍ត្រី ជឹម រតនា ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង

11. លោក ឧត្តមសេនីយ៍ត្រី ប៉ាត់ ស៊ីរ៉ូ ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង
12. លោក ឧត្តមសេនីយ៍ត្រី ស៊ុន ប៊ុនធឿន ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី
13. លោក ឧត្តមសេនីយ៍ត្រី ឱក សុភា ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល
14. លោក ឧត្តមសេនីយ៍ត្រី សំរិទ្ធ សំណាង ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តតាកែវ
15. លោក ស៊ិន សំណាង ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តត្បូងឃ្មុំ
16. លោក ឧត្តមសេនីយ៍ត្រី ម៉ៅ រុន ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តក្រចេះ
17. លោក ឧត្តមសេនីយ៍ត្រី ចាន់ សុផា ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង

ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន តំណាងមន្ទីរ អង្គភាពពាក់ព័ន្ធចំណុះ រដ្ឋបាលខេត្តសៀមរាប និងមន្ត្រីបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សរុបចំនួន៩៩រូប ស្រី១៣រូប ។

## III. **មតិស្វាគមន៍ និងចូលរួមប្រធានប្រតិភូ នៃប្រទេសទាំងបី**

១.**ឯកឧត្តម សំកុល សុចិត្រា** អភិបាលរងខេត្តសៀមរាប តំណាង ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្ត មានមតិស្វាគមន៍ចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី គណៈប្រតិភូ នៃប្រទេសទាំងពីរ២ និងស្វាគមន៍ចំពោះ **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** ព្រមទាំង ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន មន្ទីរជុំវិញខេត្តពាក់ព័ន្ធ ដែលបានអញ្ជើញចូលរួមកិច្ចប្រជុំត្រីភាគី កម្ពុជា ឡាវ វៀតណាម ស្តីពីកិច្ចសហការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែន នៅក្នុងខេត្តសៀមរាប។ ឯកឧត្តម បានមានមតិអរគុណចំពោះ **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** ដែលបានផ្តួចផ្តើមឱ្យមានកិច្ចប្រជុំដ៏មានសារៈសំខាន់នេះឡើង ហើយសង្ឃឹមថានឹងទទួលបានផ្លែផ្កាល្អៗសម្រាប់ប្រទេសទាំងបី ។

ឯកឧត្តម មានមតិគោរពជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រតិភូ នៃប្រទេសទាំងពីរ និង ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន អង្គភាព មន្ទីរពាក់ទាំងអស់ទទួលបានជោគជ័យគ្រប់ភារកិច្ច និងសូមជួបនូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំឃ្លៀងឃ្លាតឡើយ ។

២. ឯកឧត្តម ឧត្តមសេនីយ៍ **KHONGSAVAT BOUNLIENG** អគ្គនាយករង នៃអគ្គនាយកដ្ឋាននគរបាលសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បានឡើងមានមតិចូលរួមក្នុងកិច្ចប្រជុំត្រីភាគី កម្ពុជា ឡាវ វៀតណាម ស្តីពីកិច្ចសហការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែន នៅក្នុងខេត្តសៀមរាប ដែលរៀបចំដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃព្រះរាជាណាចក្រកម្ពុជា ។ តាមរយៈកិច្ចប្រជុំត្រីភាគីថ្ងៃនេះ យើងនឹងបន្តកិច្ចសហប្រតិបត្តិការកាន់តែល្អប្រសើរក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរមនុស្ស ក៏ដូចជាបទល្មើសផ្សេងទៀតឆ្លងកាត់ព្រំដែន គឺជាកិច្ចប្រជុំមួយដែលមានសារៈសំខាន់ក្នុងការរកដំណោះស្រាយដើម្បីជួយជនរងគ្រោះ ។

៣. វរសេនីយ៍ឯក Vu Van Dau អគ្គនាយករង នៃនាយកដ្ឋាន នគរបាលព្រហ្មទណ្ឌវៀតណាម មានមតិចូលរួមក្នុងកិច្ចប្រជុំត្រីភាគី កម្ពុជា ឡាវ វៀតណាម ស្តីពីកិច្ចសហការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែន ធ្វើឡើងនៅក្នុងខេត្តសៀមរាប ដែលរៀបចំដោយ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដឹកនាំសម្របសម្រួលដោយ **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** ។ ឯកឧត្តម បានលើកឡើងថា កិច្ចប្រជុំនេះយើងនឹងធ្វើការផ្លាស់ប្តូរបទពិសោធន៍គ្នារវាងប្រទេសទាំងបី ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែន ពីព្រោះបញ្ហានេះគឺជាបញ្ហាមួយដែលមានលក្ខណៈស្មុគស្មាញខ្លាំង ដែលមិនមែនប្រទេសណាមួយអាចអនុវត្ត ឬបង្ក្រាបតែម្នាក់ឯងបានទេ ត្រូវតែមានការចូលសហការក្នុងការទប់ស្កាត់ទាំងនៅក្នុងតំបន់ និងសកល ។ ឯកឧត្តម បានបន្តថា ក្នុងនាមប្រទេសជាប់ព្រំដែនជាមួយគ្នា យើងនឹងបន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយគ្នាលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបទល្មើសនានាដែលឆ្លងកាត់ព្រំដែន ។

៤. **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានអញ្ជើញមានប្រសាសន៍ស្វាគមន៍ចំពោះគណៈប្រតិភូ នៃប្រទេសវៀតណាម និងឡាវ ដែលបានចំណាយពេលវេលាមកចូលរួមកិច្ចប្រជុំត្រីភាគី កម្ពុជា ឡាវ វៀតណាម ស្តីពីកិច្ចសហការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែន ធ្វើឡើងនៅក្នុងខេត្តសៀមរាប នៅក្នុងប្រទេសកម្ពុជា នេះបញ្ជាក់ថាយើងនៅបន្តកិច្ចសហការល្អជាមួយគ្នាលើគ្រប់វិស័យ និងការប្តេជ្ញាចិត្ត ក្នុងការការពារ និងថែរក្សាសន្តិសុខ និងសុវត្ថិភាពប្រជាពលរដ្ឋនៃប្រទេសយើងទាំងបី ពីឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេស អំពើជួញដូរមនុស្សដែលកេងប្រវ័ញ្ច រំលោភបំពាន និងបំផ្លាញសេចក្តីសុខរបស់ប្រជាពលរដ្ឋ និងប្រទេសជាតិយើងទាំងបី យ៉ាងធ្ងន់ធ្ងរ ។ លោកជំទាវ បានបញ្ជាក់ថា បច្ចុប្បន្ននេះបទល្មើសឆ្លងដែន មានជាច្រើនប្រភេទ ដែលក្នុងនោះអំពើជួញដូរមនុស្សឆ្លងដែន ភាគច្រើន ក្នុងចំណោមជនទេសន្តរប្រវេសន៍ មិនស្របច្បាប់ ឬមិនមានឯកសារច្បាស់លាស់ នៅតែជាបញ្ហាប្រឈមដែលចាំបាច់ត្រូវយកចិត្តទុកដាក់បន្ថែមទៀត ជាពិសេស រវាងប្រទេសយើងទាំងបី។ ការកេងប្រវ័ញ្ចលើជនងាយរងគ្រោះ មានច្រើនរូបភាព រួមទាំងការជ្រើសរើសពលករចំណាកស្រុកក្នុងគោលដៅកេងប្រវ័ញ្ច ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងខុសច្បាប់ ការរត់ពន្ធមនុស្ស ការជួញដូរកុមារ និងទារក តាមរូបភាពជ្រើសរើសស្ត្រីឲ្យពពោះ ការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញ ការឆបោកតាមអនឡាញ ជាដើម ។ លោកជំទាវ មានប្រសាសន៍បន្តថា ព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងរងនូវបន្ទុកដោះស្រាយបញ្ហាទាំងឡាយ ដែលបង្កឡើងដោយជនល្មើសជាច្រើនរូបភាព ទាំងជនជាតិខ្មែរ ទាំងជនបរទេស ដែលជាជនល្មើស និងជាជនរងគ្រោះ ហើយក៏មានការបន្លំជាជនរងគ្រោះ ក្នុបផ្សំនឹងការផ្សព្វផ្សាយបំភ្លៃ បំផ្លើសការពិត ធ្វើឲ្យប៉ះពាល់ដល់កិត្តិយសប្រទេសជាតិយ៉ាងធ្ងន់ធ្ងរ ។ ក្រៅពីពលរដ្ឋនៃប្រទេសទាំងបី ក៏មានជនបរទេសមួយចំនួនធំ បានព្យាយាមចូលមកប្រព្រឹត្តបទល្មើស និង មួយចំនួនក្លាយជាជនរងគ្រោះ នៅក្នុងប្រទេសទាំងបីផងដែរ ។ ប្រទេសទាំងបីក៏បានក្លាយជា ប្រទេសប្រភព ប្រទេសឆ្លងកាត់ និងជាប្រទេសគោលដៅសម្រាប់ឧក្រិដ្ឋជនប្រព្រឹត្តបទល្មើសជួញដូរមនុស្ស ដែលនាំឱ្យប្រេវ៉ាឡង់នៃឧក្រិដ្ឋកម្មមានការកើនឡើងគួរឱ្យព្រួយបារម្ភ ។ ការធ្វើប្រតិបត្តិការឆបោកតាមរយៈការអូសទាញ ជ្រើសរើសការងារខុសច្បាប់ និងបង្ខំឱ្យប្រព្រឹត្តបទល្មើស ធ្វើឱ្យបទល្មើសកាន់តែមានភាពស្មុគស្មាញបន្ថែមទៀតសម្រាប់អាជ្ញាធរមានសមត្ថកិច្ច ដែលបង្កផលប៉ះពាល់ដល់

សន្តិសុខជាតិ សន្តិសុខក្នុងតំបន់ និងសាកលលោក ។ ហេតុដូចនេះ ទើបប្រទេសយើងទាំងបីដែលមានព្រំដែនជាប់គ្នា ជាប្រទេសភូមិផងរបងជាមួយ ចាំបាច់ត្រូវពិភាក្សា ផ្លាស់ប្តូរយោបល់ បទពិសោធន៍ និងរៀនសូត្រពីគ្នាទៅវិញទៅមក ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរួមគ្នា ប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ លោកជំទាវ មានប្រសាសន៍បន្តថា ជាថ្មីម្តងទៀត ក្នុងនាមប្រទេសទទួលរៀបចំកិច្ចប្រជុំនេះ សូមថ្លែងអំណរគុណដល់រដ្ឋាភិបាល នៃប្រទេសទាំងបី ដែលបានអនុញ្ញាតិឲ្យក្រុមការងារបច្ចេកទេសទាំងបី បានជួបពិភាក្សា សិក្សាស្វែងយល់ពីគ្នាទៅវិញទៅមក ជាលើកទីមួយ និងអាចមានគំនិតផ្តួចផ្តើមបន្តទៀត ក្នុងការដោះស្រាយបញ្ហារួម គឺការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្លងដែន ការការពារសុវត្ថិភាព សន្តិសុខ ប្រជាពលរដ្ឋ និងការពង្រឹងសាមគ្គីភាព កិច្ចសហការត្រីភាគី (កម្ពុជា ឡាវ វៀតណាម) ។

**លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** ប្រធានតិភូភាគីកម្ពុជា បានលើកឡើងអំពីការអនុម័តលើរបៀបវារៈ មុនបើកកិច្ចប្រជុំត្រីភាគី កម្ពុជា ឡាវ វៀតណាម ស្តីពីកិច្ចសហការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែន ។ លោកជំទាវ បានមានប្រសាសន៍ថ្លែងអំណរគុណចំពោះគណៈប្រតិភូ នៃប្រទេសទាំងពីរ ក៏ដូចជា ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន មន្ទីរពាក់ព័ន្ធចំណុះរដ្ឋបាលខេត្តសៀមរាប និងក្រុមការងារបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ទទួលបាននូវជោគជ័យគ្រប់ភារកិច្ច និងជួបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

## IV. ដំណើរការកិច្ចប្រជុំ

- របៀបវារៈទី១៖ បច្ចុប្បន្នភាព នៃការគ្រប់គ្រងលំហូរឆ្លងកាត់ព្រំដែន និងនិន្នាការនៃអំពើជួញដូរមនុស្ស
  - ការធ្វើបទបង្ហាញ ឬបទអន្តាគមន៍ ពីតំណាងប្រទេសកម្ពុជា ឡាវ វៀតណាម៖
    - បច្ចុប្បន្នភាព នៃការគ្រប់គ្រងលំហូរឆ្លងកាត់ព្រំដែន និងគោលដៅចម្បងក្នុងការឆ្លងកាត់ព្រំដែន នៃប្រទេសទាំងបី ស្តីពីជនទេសន្តរប្រវេសន៍ដែលងាយរងគ្រោះ
    - យន្តការឆ្លើយតបរបស់រដ្ឋាភិបាល នៃប្រទេសទាំងបី៖ ស្តីពីច្បាប់ គោលនយោបាយ ការអនុវត្ត និងកិច្ចសហការ
- របៀបវារៈទី២៖ បញ្ហាប្រឈមនៅក្នុងការអនុវត្ត និងការឆ្លើយតបប្រកបដោយប្រសិទ្ធភាព៖
  - ការធ្វើបទបង្ហាញ ពីតំណាងប្រទេសកម្ពុជា ឡាវ វៀតណាម៖
    - ភាពប្រឈមលើការអនុវត្តយន្តការដែលមានស្រាប់ និងបទពិសោធន៍ក្នុងការប្រមូលនិងចែករំលែកព័ត៌មាន និងទិន្នន័យរវាងប្រទេសទាំងបី
    - ការចែករំលែកនូវបទពិសោធន៍ ក្នុងការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែន និងកិច្ចសហការរវាងប្រទេសទាំងបី

❖ ភាគីកម្ពុជា

1. លោកជំទាវ ជូន ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
2. ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី អគ្គស្នងការរងនគរបាលជាតិ
3. លោក ឧត្តមសេនីយ៍ទោ សរ សិលា អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍
4. លោក ឧត្តមសេនីយ៍ត្រី ដួង ស៊ីហៃ អនុប្រធាននាយកដ្ឋាននគរបាលការពារព្រំដែនគោក

❖ ភាគីឡាវ

1. Col. Kikeo CHANTHALANGSY: Director General of Anti-Human Department, General Department of Police
2. Pol. Col Kidone KIVONGXAY: Head of Division Immigration Department

❖ ភាគីវៀតណាម

1. Senior Col. Pham Long Bien: Head of Division, Counter Narcotics Department
2. Col. Ho Thi Hong Anh: Deputy Head of Division
3. Col. Doan Van Dac: Deputy Head of Division.

➢ របៀបវារៈទី៣៖ ការចែករំលែកបទពិសោធន៍ ការអនុវត្តល្អ ភាពប្រឈមដែលនៅសេសសល់ ក្នុងការអនុវត្តនីតិវិធី និងវិធានការនានាពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ខុសច្បាប់ និងអំពើជួញដូរមនុស្សនៅក្នុងប្រទេសទាំងបី

1. លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
2. ឯកឧត្តម អ៊ឹង វ៉ាន់ថា តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
3. ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី អគ្គនស្នងការរងនគរបាលជាតិ
4. តំណាងភាគីឡាវ
5. តំណាងភាគីវៀតណាម

➢ របៀបវារៈទី៤៖ កិច្ចពិភាក្សាស្តីពី ដំណោះស្រាយរួមដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងព្រំដែន និងពង្រឹងកិច្ចសហប្រតិបត្តិការលើកកម្ពស់ការធ្វើទេសន្តរប្រវេសន៍ ប្រកបដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់

1. លោក ភាវ ខៃ តំណាង អង្គការ IOM ប្រចាំកម្ពុជា ធ្វើបទបង្ហាញ អំពី កតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់ (តាមប្រព័ន្ធអនឡាញ)
2. លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
3. ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី អគ្គនស្នងការរងនគរបាលជាតិ
4. តំណាងភាគីវៀតណាម
5. តំណាងភាគីឡាវ

## V. **លទ្ធផលកិច្ចប្រជុំ**

បន្ទាប់ពីពិភាក្សាតាមរបៀបវារៈដែលបានកំណត់ខាងលើ ប្រតិភូ នៃប្រទេសទាំងបី បានសម្រេចជាលទ្ធផលដូចខាងក្រោម៖

១.បានស្វែងយល់ពីភាពងាយរងគ្រោះចម្បងនៃជនទេសន្តរប្រវេសន៍ឆ្លងដែននៃប្រទេសទាំងបី ព្រមទាំងបានធ្វើបច្ចុប្បន្នភាពពីស្ថានភាពបច្ចុប្បន្ននៃការគ្រប់គ្រងទេសន្តរប្រវេសន៍ឆ្លងដែន និងរបត់ថ្មីនៃអំពើជួញដូរមនុស្សដូចជាការជួញដូរមនុស្សដោយប្រើប្រាស់បច្ចេកវិទ្យាទាក់ទងទំនើប។

២.បានចែករំលែកបទពិសោធន៍ជោគជ័យ និងបញ្ហាប្រឈមនៃយន្តការឆ្លើយតបរបស់រាជរដ្ឋាភិបាលនៃប្រទេសទាំងបី។

៣.បានទទួលស្គាល់នូវតម្រូវការនៃការពង្រឹងបន្ថែមនូវកិច្ចសហប្រតិបត្តិការក្នុងចំណោមអាជ្ញាធរពាក់ព័ន្ធនៃប្រទេសទាំងបី ដើម្បីបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព នៃការគ្រប់គ្រងព្រំដែន ការពារជនងាយរងគ្រោះពីស្ថានភាពហានិភ័យដែលបង្កដោយបណ្តាញជនល្មើស។

៤.បានកត់សម្គាល់ឃើញថា សកម្មភាពបង្ការទប់ស្កាត់ គួរតែត្រូវបានផ្តល់អាទិភាព ដោយសារការបង្ការទប់ស្កាត់ មានភាពចាំបាច់ក្នុងការការពារមនុស្សពីគ្រប់ទម្រង់នៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ច ក្នុងនោះធ្វើឡើងតាមរយៈយុទ្ធនាការលើកកម្ពស់ការយល់ដឹងនៅកម្រិតសហគមន៍ ពីទេសន្តរប្រវេសន៍ខុសច្បាប់ និងអំពើជួញដូរមនុស្ស។

៥.បានព្រមព្រៀងធ្វើការពិភាក្សាបន្ថែមលើការបង្កើតនូវយន្តការចែករំលែកព័ត៌មាន ដើម្បីឆ្លើយតបទៅនឹងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ច និងដើម្បីបង្កើនជំនួយសម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។

៦.បានព្រមព្រៀងឱ្យមានកិច្ចប្រជុំតាមដានត្រីភាគី ដើម្បីពិភាក្សាលើការត្រៀមរៀបចំសកម្មភាពបន្តបន្ទាប់ដែលបានព្រមព្រៀងគ្នាដោយប្រតិភូនៃប្រទេសទាំងបី។

- **កំណត់សម្គាល់**

លទ្ធផលខាងលើនេះ ប្រតិភូនៃប្រទេសទាំងបី (កម្ពុជា ឡាវ វៀតណាម) បានឯកភាពគ្នាជាគោលការណ៍ ប៉ុន្តែសម្រាប់ប្រតិភូវៀតណាម ស្នើសុំមិនទាន់ចុះហត្ថលេខាលើកំណត់ហេតុនៃកិច្ចប្រជុំភ្លាមៗនោះទេ ដោយរង់ចាំគោរពសុំការអនុញ្ញាត និងរាយការណ៍ជូនថ្នាក់ដឹកនាំ នៃប្រទេសវៀតណាមជាមុនសិន ដោយសន្យានឹងបញ្ជូនលិខិតឆ្លើយតបជាផ្លូវការវិញមុនថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៥។ ផ្អែកតាមសំណើរបស់ប្រតិភូវៀតណាម កំណត់ហេតុ នៃកិច្ចប្រជុំមិនបានចុះហត្ថលេខាទេ ដោយរង់ចាំលិខិតឆ្លើយតបជាផ្លូវការរបស់ប្រតិភូវៀតណាម។

## VI. ចំណាប់អារម្មណ៍ និងសុន្ទរកថាបិទកិច្ចអង្គប្រជុំ

- ចំណាប់អារម្មណ៍លើកិច្ចប្រជុំដោយតំណាងប្រតិភូប្រទេសឡាវ
- ចំណាប់អារម្មណ៍លើកិច្ចប្រជុំដោយតំណាងប្រតិភូប្រទេសវៀតណាម
- សុន្ទរកថាបិទកិច្ចប្រជុំដោយ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កម្ពុជា

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់ពីរ សាមសិបនាទី ក្រោមបរិយាកាសរីករាយ និងស្និទស្នាលរវាងប្រតិភូនៃប្រទេសទាំងបី។

ថ្ងៃអង្គារ ៩រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៤

**អ្នកធ្វើកំណត់ហេតុ**

**ប្រធាន**

ឧត្តមសេនីយ៍ទោ កែវ សុវណ្ណារ៉ា

អានយល់ 30/12/24

ជូ_ប៊ុនអេង